**JICA Cambodia Office - JICA カンボジア事務所**

October 10 at 10:08 AM ·

**[កិច្ចប្រជុំលើកទី ៣ របស់គណៈកម្មការសម្របសម្រួល នៃគម្រោង Strings / The 3rd Joint Coordination Committee Meeting (JCC), Strings Project]**

------------------------------

**កិច្ចប្រជុំគណៈកម្មការសម្របសម្រួលលើកទី ៣ បានរៀបចំឡើងដោយក្រសួងសុខាភិបាល និងគម្រោង Strings នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០២៣ ក្រោមអធិបតីភាពរបស់ ឯកឧត្តម សាស្ត្រាចារ្យ ជា គ្រុយ រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល និងជានាយកគម្រោងថ្មី។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណង (១) ពិនិត្យពីវឌ្ឍនភាពនៃសកម្មភាពគម្រោងចាប់ពីខែកុម្ភៈ ដល់ខែសីហា ឆ្នាំ២០២៣ (២) ចែករំលែកនូវសមិទ្ធផលពីការចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន និង(៣) ដើម្បីកំណត់ផែនការសម្រាប់រយៈពេល ៦ ខែបន្ទាប់។**

**កិច្ចប្រជុំនេះ ក៏មានការអញ្ជើញចូលរួមពី លោក SANUI Kazumasa ប្រធានទីភ្នាក់ងារ JICA ប្រចាំប្រទេសកម្ពុជា និងតំណាងផ្សេងៗមកពីក្រសួងសុខាភិបាល ទីស្នាក់ការកណ្តាល JICA នៅប្រទេសជប៉ុន (តាមរយៈ Zoom) ស្ថានទូតជប៉ុន(តាមរយៈ Zoom) គណៈគិលានុបដ្ឋាកកម្ពុជា (CCN) សមាគមគិលានុបដ្ឋាកកម្ពុជា (CAN) មន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត មន្ទីរពេទ្យបង្អែកខេត្ត និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ នៃខេត្តបាត់ដំបង និងកំពង់ចាមដែលជាខេត្តសាកល្បងរបស់គម្រោង។**

**អត្ថបទ និងរូបថត៖ គម្រោង Strings**

**The 3rd JCC meeting was co-organized by the Ministry of Health (MoH) and the Strings Project on September 29, 2023, and was presided over by H.E. Prof. THIR Kruy, the Ministry of Health's Secretary of State, and the newly appointed Project Director. The event was conducted to report on the ongoing progress of the project activities from February to September 2023, to share the achievement of the training in Japan, and to outline the plan for the upcoming six months.**

**Mr. SANUI Kazumasa, Chief Representative from JICA Cambodia Office, and other representatives from MOH, JICA Headquarters (HQ) in Japan (via Zoom) Embassy of Japan (via Zoom), Cambodian Council of Nurses (CCN), Cambodian Association of Nurses (CAN), national hospitals, provincial administration health departments, provincial hospitals, and regional training centers in pilot provinces (Battambang and Kampong Cham) were among the honorable attendees.**

**Article and photos Credited: Strings Project**


















